**សលាកប័ត្រព័ត៌មាន** ៖ កម្រងឯកសារស្តីពីស្ថាប័ន ៖ តុលាការឧទ្ធរណ៍របស់កម្ពុជា

**ស្ថាប័ន** ៖ តុលាការឧទ្ធរណ៍របស់កម្ពុជា ("សាលាឧទ្ធរណ៍")

**រូបភាពរួម** ៖ តុលាការឧទ្ធរណ៍គឺជាសាលាឧទ្ធរណ៍ថ្នាក់កណ្តាល ស្ថិតនៅក្នុងរាជធានីភ្នំពេញ ដែលត្រូវបានផ្តល់អំណាចដើម្បីជំនុំជម្រះបណ្តឹងឧទ្ធរណ៍ទាំងឡាយពាក់ព័ន្ធនឹងច្បាប់ និង/ឬអង្គហេតុក្នុងសាលក្រមរដ្ឋប្បវេណី និងព្រហ្មទណ្ឌដែលបានវិនិច្ឆ័យក្តីនៅសាលាដំបូងទាំងអស់នៅព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា") ។ រាល់ដំណាក់កាលនៃការបង្កើតសាលាឧទ្ធរណ៍នៅតាមតំបន់ នឹងបង្កើនលទ្ធភាពក្នុងការទទួលបាននីតិវិធីបណ្តឹងឧទ្ធរណ៍ ដល់ប្រជាពលរដ្ឋកម្ពុជា ដែលមានបំណងដាក់សាលក្រមព្រហ្មទណ្ឌ ឬរដ្ឋប្បវេណី ប៉ុន្តែបានជួបឧបសគ្គដោយខ្លួនរស់នៅក្នុងតំបន់ដាច់ស្រយោល និងកង្វះខាតមធ្យោបាយធ្វើដំណើរមកកាន់រាជធានីភ្នំពេញ និងហេតុដូច្នេះហើយ ការបង្កើតសាលាឧទ្ធរណ៍នៅតាមតំបន់បង្ហាញពីជំហានវិជ្ជមាននៃលទ្ធភាពទទួលបានយុត្តិធម៌នៅកម្ពុជា ។

## សេចក្តីផ្តើម

យោងតាមរបាយការណ៍ថ្មីៗនេះដែលក្រសួងយុត្តិធម៌ ("ក.ស.យ") គ្រោងនឹងបង្កើតសាខាតុលាការឧទ្ធរណ៍នៅតាមតំបន់ក្នុងបណ្តាលខេត្តនានា សលាកប័ត្រព័ត៌មាននេះផ្តល់សេចក្តីសង្ខេបអំពីតួនាទី និងមុខងាររបស់តុលាការឧទ្ធរណ៍ ព្រមទាំងប្រសិទ្ធភាពនៃតុលាការនេះ ក្នុងបរិបទនៃបញ្ហាចម្បងៗពាក់ព័ន្ធនឹងលទ្ធភាពទទួលបានយុត្តិធម៌ក្នុងប្រទេសកម្ពុជា ។ សលា-កប័ត្រនេះតាក់តែងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ដែលជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធ ធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅកម្ពុជា ។

## តុលាការឧទ្ធរណ៍

តុលាការឧទ្ធរណ៍គឺជាសាលាឧទ្ធរណ៍ថ្នាក់កណ្តាល ដែលស្ថិតនៅរាជធានីភ្នំពេញ ប៉ុន្តែយុត្តាធិការរបស់តុលាការនេះគ្របដណ្តប់ទូទាំងប្រទេសកម្ពុជា ។ តុលាការឧទ្ធរណ៍ជំនុំជម្រះក្តីដែលប្តឹងឧទ្ធរណ៍ពីសាលាដំបូងនៅរាជធានី និងខេត្ត ព្រមទាំងតុលាការយោធា (ករណីជនជាប់ចោទគឺជាយោធិន) ។ តុលាការឧទ្ធរណ៍ជំនុំជម្រះបណ្តឹងឧទ្ធរណ៍ទាំងអស់ពាក់ព័ន្ធនឹងច្បាប់ និងអង្គហេតុប្រឆាំងនឹងសាលក្រមព្រហ្មទណ្ឌ និងរដ្ឋប្បវេណី ។ ទោះជាយ៉ាងណាក៏ដោយ តុលាការឧទ្ធរណ៍មិនមែនជាតុលាការដែលទទួលបណ្តឹងឧទ្ធរណ៍ថ្នាក់ខ្ពស់បំផុតក្នុងប្រទេសកម្ពុជាឡើយ ដែលបណ្តឹងឧទ្ធរណ៍អាចដាក់ទៅកាន់តុលាការកំពូលចំពោះ (១) អង្គច្បាប់ និង (២) អង្គច្បាប់ និងអង្គហេតុ ។ តុលាការកំពូលគឺជាតុលាការឧទ្ធរណ៍ថ្នាក់ខ្ពស់បំផុតនៅកម្ពុជា ។

ភាគីដែលមិនពេញចិត្តនឹងសាលក្រម ឬសេចក្តីសម្រេច អាចប្តឹងឧទ្ធរណ៍ដោយដាក់បណ្តឹងឧទ្ធរណ៍នៅការិយាល័យស្មៀនសាលាដំបូង ដែលបានចេញសាលក្រមដំបូង ។ មាត្រា៣៧៧នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ("ក.ន.ព.ក") បានចែងជាពិសេសអំពីសិទ្ធិរបស់ជនជាប់ទោសដែលត្រូវបានឃុំខ្លួន ក្នុងការបន្តនីតិវធីបណ្តឹងឧទ្ធរណ៍ តាមរយៈប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនដែលពួកគេត្រូវបានឃុំខ្លួន ។ ទោះបីជាភាគីរដ្ឋប្បវេណីនៅមានសិទ្ធិដាក់បណ្តឹងឧទ្ធរណ៍ក៏ដោយ ពួកគេអាចប្តឹងឧទ្ធរណ៍ដោយផ្អែកលើផល-ប្រយោជន៍ជាពលរដ្ឋរបស់ពួកគេតែប៉ុណ្ណោះ ជាពិសេសចំនួននៃប្រាក់សំណងដែលត្រូវបានផ្តល់ជូន ឬការបដិសេធមិនផ្តល់សំណង ហើយពួកគេមិនអាចដាក់សំណើថ្មីមកកាន់តុលាការឧទ្ធរណ៍ ដោយមិនបានដាក់សំណើ ទៅកាន់សាលាដំបូងជាមុនបានឡើយ (មាត្រា៤០២នៃ ក.ន.ព.ក) ។ ទាំងភាគីរដ្ឋប្បវេណី និងជនជាប់ទោសមានរយៈពេលមួយខែក្នុងការប្តឹងឧទ្ធរណ៍ (មាត្រា៣៨២នៃ ក.ន.ព.ក) ។

នីតិវិធីនៅតុលាការឧទ្ធរណ៍ត្រូវបានជំនុំជម្រះដោយចៅក្រមបីរូប ហើយត្រូវធ្វើឡើងជាសាធារណៈ លើកលែងតែក្នុងករណីដែលតុលាការឧទ្ធរណ៍មើលឃើញថាការជំនុំជម្រះជាសាធារណៈ *"អាចបណ្តាលឲ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សណ្តាប់ធ្នាប់សង្គម ឬសីលធម៌"* (មាត្រា៣៩២នៃ ក.ន.ព.ក) ។ តុលាការឧទ្ធរណ៍អាចបញ្ជាក់ កែប្រែ ឬបដិសេធសេចក្តីសម្រេចដែលមានពាក់ព័ន្ធរបស់សាលាដំបូងទាំងស្រុង ឬដោយផ្នែក រួមទាំងការកែប្រែសេចក្តីសម្រេចទោស និងជំនួសសេចក្តីសម្រេចនេះដោយសេចក្តីសម្រេចមិនចោទប្រកាន់ក្នុងករណីព្រហ្មទណ្ឌ បន្ទាប់ពីមានការជំនុំជម្រះក្តី (មាត្រា៤០៥ ដល់៤០៦នៃ ក.ន.ព.ក) ។ ប្រសិនបើតុលាការឧទ្ធរណ៍កែប្រែការផ្តន្ទាទោសដែលសម្រេចដោយសាលាដំបូង ការផ្តន្ទាទោសរបស់សាលាដំបូងមិនត្រូវបានធ្វើឲ្យកាន់តែធ្ងន់ធ្ងរ (ដូចជាការបន្ថែមទោស) ឡើយ ទោះបីជាក្នុងករណីដែលតុលាការឧទ្ធរណ៍សម្រេចធ្វើចំណាត់ថ្នាក់ បទល្មើសដែលសាលាដំបូងបានផ្តន្ទាទោសឡើងវិញ (មាត្រា៣៩៩នៃ ក.ន.ព.ក) ក៏ដោយ ។

## លទ្ធភាពទទួលបានយុត្តិធម៌នៅកម្ពុជា

លទ្ធភាពទទួលបានយុត្តិធម៌គឺជាបញ្ហាចម្បងក្នុងប្រព័ន្ធតុលាការកម្ពុជា ដែលភាពក្រីក្រ និងការអប់រំក្នុងស្រុកអំពីសិទ្ធិបុគ្គលនៅមានកម្រិត ប៉ះពាល់ដល់លទ្ធភាពរបស់ប្រជាពលរដ្ឋកម្ពុជាក្នុងការទទួលបានការពិគ្រោះផ្នែកច្បាប់ និងតំណាងផ្នែកច្បាប់ដើម្បីបង្កើតនីតិវិធីរដ្ឋប្បវេណី និងថែមទាំងការពារខ្លួនពួកគេក្នុងនីតិវិធីព្រហ្មទណ្ឌ ។ ពិតប្រាកដណាស់ បញ្ហានេះរួមមានការបង្កើត និងការឆ្លើយតបនឹងនីតិវិធីប្តឹងឧទ្ធរណ៍ ។ បញ្ហានេះមានលក្ខណៈធ្ងន់ធ្ងរនៅទីជនបទនៅកម្ពុជា ដែលប្រជាពលរដ្ឋជាច្រើនរស់នៅក្នុងភាពក្រីក្រតោកយ៉ាក ដោយមិនអាចឈប់ពីការងារ និងធ្វើដំណើរផ្លូវឆ្ងាយដើម្បីចូលរួមក្នុងនីតិវិធីតុលាការបាន ។

ក្នុងបរិបទនីតិវិធីព្រហ្មទណ្ឌ សិទ្ធិរបស់ជនជាប់ទោសក្នុងការសុំឲ្យមានការពិនិត្យការផ្តន្ទាទោសឡើងវិញ និងកាត់ទោសពួកគេទៅតាមច្បាប់ដោយតុលាការថ្នាក់ខ្ពស់ជាងនេះ គឺជាសិទ្ធិមនុស្សមូលដ្ឋានដែលមានចែងក្នុងមាត្រា១៤(៥) នៃកតិកាសញ្ញាអន្តរ-ជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ("ក.អ.ស.ព.ន") ដែលកម្ពុជាបានចុះហត្ថលេខា និងផ្តល់សច្ចាប័ននៅឆ្នាំ១៩៩២ ហើយបានបញ្ចូលក្នុងច្បាប់ជាតិ តាមរយៈមាត្រា៣១នៃរដ្ឋធម្មនុញ្ញកម្ពុជា ។ ការដាក់កម្រិតលើសិទ្ធិនេះដោយការធ្វើឲ្យដើមបណ្តឹងឧទ្ធរណ៍ និងក្រុមគ្រួសារព្រមទាំងអ្នកគាំទ្រពួកគេមានការលំបាក និងត្រូវចំណាយថវិកាច្រើន ក្នុងការធ្វើដំណើរមកកាន់តុលាការឧទ្ធរណ៍ថ្នាក់កណ្តាល បណ្តាលឲ្យមិនមានការឆ្លើយតប ចំពោះការធានាដែលមានចែងក្នុងមាត្រា១៤(៥) នៃក.អ.ស.ព.ន ហើយមានភាពលំបាកក្នុងការអនុវត្តន៍ ។ ករណីនេះបានបញ្ជាក់ពីមូលហេតុដែលថាមាត្រា៣៨៩នៃក.ន.ព.ក តម្រូវឲ្យដើមបណ្តឹងឧទ្ធរណ៍ដែលត្រូវបានឃុំខ្លួន ត្រូវបានបញ្ជូនដោយមិនពន្យារពេលទៅកាន់ពន្ធនាគារ ឬមណ្ឌលឃុំខ្លួនដែលនៅជិតតុលាការឧទ្ធរណ៍បំផុត ។ យោងតាមមាត្រា៤១៥នៃ ក.ន.ព.ក ប្រសិនបើដើមបណ្តឹងឧទ្ធរណ៍ត្រូវបានកោះហៅត្រឹមត្រូវ ប៉ុន្តែមិនមានវត្តមាននៅក្នុងពេលជំនុំជម្រះ តុលាការអាចនឹងប្រកាសថាការបណ្តឹងជំទាស់ត្រូវបានចាត់ទុកជាមោឃៈ ។ បន្ទាប់មក សាលក្រមកំបាំងមុខនេះនឹងមិនអាចត្រូវបានកែប្រែឡើយ ហើយមានប្រសិទ្ធភាពអនុវត្តចំពោះភាគីទាំងអស់ ។ ទោះជាយ៉ាងណាក៏ដោយ ដើមបណ្តឹងឧទ្ធរណ៍ត្រូវបានអនុញ្ញាតឲ្យបញ្ជូនសំនុំរឿងរបស់ខ្លួនទៅកាន់តុលាការកំពូលបាន ។

នៅខែមេសា ឆ្នាំ២០១២ សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស ("លីកាដូ") បានចេញផ្សាយលិខិតសង្ខេប ដែលមានចំណងជើងថា *"កាត់ទោសកំបាំងមុខនៅឆ្នាំ២០១២ ៖ ការធ្វើបច្ចុប្បន្នភាពអំពីវិបត្តិនៃការដឹកជញ្ជូនអ្នកជាប់ឃុំ និងសិទ្ធិប្តឹងឧទ្ធរណ៍"* បន្ទាប់ពីរបាយការណ៍ចេញឆ្នាំ២០១០ ដែលបានរកឃើញ "ការកើនឡើង" នៃការប្តឹងឧទ្ធរណ៍*កំបាំងមុខ*ក្នុងប្រទេសកម្ពុជា ។ លីកាដូបានរកឃើញការធ្លាក់ចុះបន្តិចបន្តួចនូវចំនួនអ្នកជាប់ឃុំ ដែលបណ្តឹងឧទ្ធរណ៍ត្រូវបានពន្យារពេល (ដែលធ្លាក់ចុះដល់ ១៥,៤% ពី១៧% ក្នុងឆ្នាំ២០១០) ទោះបីជាសរុបមកមានអ្នកជាប់ឃុំប្រមាណ៨០០នាក់បានឲ្យដឹងថា ពួកគេស្ថិតនៅក្នុងស្ថានភាពមួយដែលអគ្គនាយក-ដ្ឋានពន្ធនាគារមិនមានយានជំនិះ ប្រេងឥន្ធនៈ បុគ្គលិក និងមូលនិធិគ្រប់គ្រាន់ ដែលចាំបាច់សម្រាប់ដឹកជញ្ជូនទណ្ឌិតទាំងនេះទៅកាន់ការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ។ ពួកគេបានដឹងថាដំណោះស្រាយតែមួយគត់សម្រាប់ទណ្ឌិតដែលមានបំណងចូលរួមក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ គឺពួកគេត្រូវចំណាយថវិកាខ្លួនឯង ដែលជាជម្រើសមួយដ៏លំបាក ឬមិនអាចទៅរួចសម្រាប់ប្រជាពលរដ្ឋភាគច្រើននៅប្រទេសកម្ពុជា ។

## ការសន្និដ្ឋាន

ការបង្កើតតុលាការឧទ្ធរណ៍តំបន់ ដែលគ្របដណ្តប់ស្រុកក្នុងតំបន់គោលដៅ រួមមានខេត្តជាច្រើនក្នុងតំបន់ភូមិសាស្ត្រជាក់លាក់ គឺជាអនុសាសន៍មួយក្នុងចំណោមអនុសាសន៍ទាំងអស់ ដែលមានក្នុងរបាយការណ៍របស់អង្គការលីកាដូ ។ ម.ស.ម.ក ក៏សូមស្វាគមន៍គម្រោងរបស់ ក.ស.យ ក្នុងការបង្កើតឲ្យមានសាខាឧទ្ធរណ៍នៅតាមខេត្តជាជាងមានតែមួយដូចបច្ចុប្បន្ន ថាជាជំហានវិជ្ជមានមួយ ដែលជាចុងក្រោយឆ្ពោះទៅរកការដោះស្រាយកង្វះខាតមូលនិធិ និងធនធានក្នុងប្រព័ន្ធពន្ធនាគារ ពាក់ព័ន្ធនឹងការដឹកជញ្ជូនដើមបណ្តឹងឧទ្ធរណ៍ទៅកាន់ការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ។ ជំហាននេះនឹងបង្កើនលទ្ធភាពទទួលបាននីតិវិធីបណ្តឹងឧទ្ធរណ៍ សម្រាប់ប្រជាពលរដ្ឋកម្ពុជា ដែលមានបំណងដាក់បណ្តឹងឧទ្ធរណ៍ព្រហ្មទណ្ឌ ឬរដ្ឋប្បវេណី ប៉ុន្តែជួបឧបសគ្គដោយខ្លួនរស់នៅក្នុងតំបន់ដាច់ស្រយាល និងកង្វះខាតមធ្យោបាយធ្វើដំណើរមកកាន់រាជធានីភ្នំពេញ

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង លោក អ៊ូ វីរៈ (+៨៥៥ (0) ១២ ៤០ ៤០ ៥១ ឬអ៊ីម៉ែល៖** ouvirak@cchrcambodia.org **ឬកញ្ញា សាណា ហ្គោស (+៨៥៥ (0) ៨៩ ៦១ ៤៣ ៣៤ ឬអ៊ីម៉ែល៖** sana.ghouse@cchrcambodia.org **។**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights
CC BY NC SA